# មាតាបិតាក៏រាប់ផងដែរ

## ការជួយកូនរបស់លោកអ្នកនៅក្នុង – ការធ្វើតំណាង ហើយបកស្រាយគំនូសតាង និងតារាង

នៅក្នុងការរស់នៅប្រចាំថ្ងៃរបស់យើង យើងត្រូវបានរំពឹងឲ្យមានការដឹងយល់នូវព័ត៌មានដែលតំណាងនៅក្នុងគំនូសតាង និងតារាង។ យើងឃើញប្រភេទនៃព័ត៌មាននេះមាននៅក្នុងសារព័ត៌មាន និងកូនសៀវភៅទាំងឡាយនៅពីលើវិក្កយបត្រ និងនៅក្នុងទូរទស្សន៍។ គំនូសតាងអាចធ្វើឲ្យមានការងាយស្រួលក្នុងការធ្វើកំណត់ត្រា ហើយបកស្រាយព័ត៌មាន ថែមទាំងជួយយើងក្នុងការទាយទុកជាមុនដូច ជាការទាយទុកពីអាកាសធាតុ អត្រាការប្រាក់ និងតម្លៃទៅអនាគតនៃការប្រើប្រាស់អគ្គិសនីរបស់យើងនៅផ្ទះ។ កុមារនឹងរៀនចេះអាន ហើយបកស្រាយគំនូសតាង និងតារាង មិនត្រឹមតែក្នុងអម្លុងមេរៀនគិតសាស្ត្រប៉ុណ្ណោះទេ ក៏ប៉ុន្តែគេក៏រៀនចេះផងដែរនូវមេរៀនវិទ្យាសាស្ត្រ សុខភាព និងមេរៀនឯទៀត។

## តើកុមាររៀនចេះធ្វើ និងបកស្រាយគំនូសតាង និងតារាងដោយបែបណា?

ជាដំបូង កុមាររៀនចេះផ្គុំតារាងដោយប្រមូលនូវព័ត៌មានចេញពីតារាង បន្ទាប់មកប្រើវត្ថុ និងរូបភាពទាំងឡាយដើម្បីធ្វើតំណាងព័ត៌មាននេះចេញជាគំនូសតាង។ ធម្មតា នៅក្នុងឆ្នាំដំបូង គ្រូបង្រៀននឹងប្រាប់ឲ្យកុមារប្រមូល ហើយកត់ចុះនូវព័ត៌មានអំពីខ្លួនគេ ដូចជាសត្វចិញ្ចឹមដែលគេមាន ឬអំពីបរិដ្ឋានដែលមាននៅជុំវិញគេដូចជាពណ៌ឡានទាំងឡាយដែលនៅកន្លែងចតឡាន។ នៅក្នុងគំនូសតាងដើម រូបភាពមួយ ធ្វើជាតំណាងវត្ថុមួយ។

ក្រោយៗមក កុមារនឹងរៀនចេះប្រើសញ្ញាបូកបញ្ចូលគ្នា (ឧទាហរណ៍ 卌 III) ដើម្បីធ្វើជាតំណាងលទ្ធផលនៃការស្ទង់មតិ។ ឧទាហរណ៍ គេអាចប្រាប់ឲ្យប្រើសញ្ញាបូកបញ្ចូលគ្នា ដើម្បីកត់ចុះនូវចំនួនឡានដែលបើកកាត់សាលារៀនក្នុងអម្លុងពេលកំណត់ណាមួយ។ គេក៏នឹងបានណែនាំឲ្យស្គាល់ផងដែរនូវប្រភេទខុសៗគ្នានៃគំនូសតាងឯទៀត មានរួមទាំងគំនូសតាងជាខ្ទង់ ឬជួរ (column graphs) គំនូសតាងជាខ្សែ (line graphs) ឬគំនូសតាងជានំផាយ (pie graphs)។ នេះគឺជាការសំខាន់ដែលកុមារត្រូវដឹងអំពីរបៀបបកស្រាយគំនូសតាង ហើយអាចសម្គាល់ដឹងពីរបៀបដែលគំនូសតាងអាចធ្វើជាតំណាងព័ត៌មានខុស។



## តើលោកអ្នកអាចធ្វើអ្វីបានខ្លះនៅផ្ទះ?

- វាស់កំពស់ ឬទម្ងន់របស់កូនរបស់លោកអ្នក ហើយតាមដានកត់មើលការផ្លាស់ប្តូរពីកាលកន្លងទៅនៅលើគំនូសតាង។
- ពេលក្រោយដែលលោកអ្នកមើលឃើញគំនូសតាងណាមួយនៅក្នុងសារព័ត៌មាន ស្តីអំពីប្រធានបទណាមួយដែលគួរឲ្យចាប់ចិត្តដល់កូនរបស់លោកអ្នក សូមអង្គុយចុះជាមួយកូនរបស់លោកអ្នក ហើយបកស្រាយពីគំនូសតាងនោះជាមួយគ្នា។ រៀនដោះស្រាយសំនួរជាមួយគ្នាដូចជា: *តើគំនូសតាងនេះនិយាយប្រាប់យើងអំពីអ្វី? តើធ្វើដូចម្តេចឲ្យយើងដឹងថាព័ត៌មាននេះពិត? តើមានវិធីផ្សេងទៀតឬទេក្នុងការបកស្រាយព័ត៌មាននេះ? តើមានអ្វីណាទៀតដែលអ្នកមិនយល់ឬទេ?*

NEW SOUTH WALES DEPARTMENT OF EDUCATION AND TRAINING

© State of New South Wales through the NSW Department of Education and Training, 2007.



- បង្ហាញដល់កូនរបស់លោកអ្នកនូវវិក្កយបត្រកិច្ចការក្នុងផ្ទះដែលមានរួមគំនូសតាង ដូចជាថ្លៃទឹក ឬថ្លៃអគ្គិសនី ហើយសួរសំនួរទាំងឡាយដូចជាៈ *តើពេលនេះយើងប្រើអស់ទឹកច្រើន ឬតិច ប្រសិនបើប្រៀបធៀបទៅនឹងវិក្កយបត្រទឹកដែលយើងប្រើកាលពីលើកមុន ក្នុងពេលដូចគ្នានេះ? តើយើងអាចសន្សំទឹកឲ្យបានច្រើនដោយបែបណា? តើយើងនឹងប្រើអស់ទឹកតិចប៉ុន្មានដែរ ប្រសិនបើយើងធ្វើដូច្នេះ? តើអ្នកយល់ថាយើងនឹងចំណេញប្រាក់បានប៉ុន្មាន?*
- ជាមួយកូនរបស់លោកអ្នក ចូររក្សាកត់ចុះនូវចំនួនម៉ោងដែលកូនរបស់លោកអ្នកបានចំណាយមើលទូរទស្សន៍។ នៅចុងសប្តាហ៍ សាកល្បងធ្វើគំនូសតាងដើម្បីបង្ហាញពីចំនួនម៉ោងដែលកូនរបស់លោកអ្នកបានចំណាយមើលទូរទស្សន៍។
- លេងល្បែងកំសាន្តទាំងឡាយដូចជា *កន្ត្រៃ ក្រដាស ថ្ម* (*Scissors, paper, rock*) ជាមួយកូនរបស់លោកអ្នក ហើយប្រើសញ្ញាបូកបញ្ចូលគ្នា ដើម្បីរក្សានូវកំណត់ត្រានៃចំនួនដែលឈ្នះ និងចាញ់។
- ជាមួយកូនរបស់លោកអ្នក ចូរអាន ហើយពិភាក្សាព័ត៌មានដែលបង្ហាញនៅក្នុងតារាងប្រកួតប្រជែងកីឡា។
- អានសៀវភៅព័ត៌មានជាមួយកូនរបស់លោកអ្នក ហើយពិភាក្សាអំពីតារាង និងគំនូសតាងដែលបង្ហាញនៅក្នុងសៀវភៅនោះ។
- បង្ហាញប្រាប់កូនរបស់លោកអ្នកអំពីរបៀបរកឃើញ ហើយប្រើតារាងអត្ថបទនៅក្នុងសៀវភៅមួយ។
- គូសតារាងនៃសកម្មភាពដែលកូនរបស់លោកអ្នកបំពេញនៅក្នុងអម្លុងសប្តាហ៍ ដូចជាការហ្វឹកហ្វឺនកីឡា ការហាត់ចំរៀង ឬការរៀនហែលទឹក កិច្ចការក្នុងផ្ទះ ឬពេលពិសេសទាំងឡាយក្នុងអម្លុងសប្តាហ៍រៀនសូត្រដូចជាបណ្ណាល័យ ខុមព្យូធើរ កីឡាសាលា និងការទៅធនាគារ។



NEW SOUTH WALES DEPARTMENT OF EDUCATION AND TRAINING

© State of New South Wales through the NSW Department of Education and Training, 2007.